# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង

## រវាង

## នាយកក្រុមហ៊ុន ហ្ស៊ីជាង ហេងហ្វេង ថប លេហ្សឺរ (ខេមបូឌា) ឯ.ក

## ជាមួយប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃពីរ ខែសីហា ថ្ងៃទីសាមសិប វេលាម៉ោងដប់ និងប្រាំនាទី នៅការិយាល័យក្រុមហ៊ុន **ហ្ស៊ីជាង ហេងហ្វេង ថប លេហ្សឺរ (ខេមបូឌា) ឯ.ក** / ZHEJIANG HENGFENG TOP LEISURE CAMBODIA CO.,LTD មានកិច្ចប្រជុំពិភាក្សា រវាងនាយក្រុមហ៊ុន និងប្រតិភូ-បុគ្គលិកប្រចាំក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារ ដោយមូលហេតុថា នៅពេលថ្មីៗនេះ ដោយសារកង្វះការបញ្ជាទិញ ដែលជាបញ្ហាដ៏ធំមួយបណ្តាលឲ្យស្ទះលំហូរនៃផលិតកម្មយ៉ាងធ្ងន់ធ្ងរ ។

ហេតុដូចនេះ ក្រោយពីបានពិភាក្សាគ្នារួចមក ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោមៈ

១- ភាគីទាំងពីរយល់ព្រមព្យួរកិច្ចសន្យាការងាររយៈពេលពីរខែ គិតចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ រហូតដល់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ ។

២- ក្រុមហ៊ុននឹងធ្វើការជូនដំណឹងទៅប្រធានក្រុមទាំងអស់ក្នុងករណីមានការបញ្ជាទិញឡើងវិញ បានក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ។ ហើយប្រធានក្រុមគ្រប់ផ្នែកគ្រប់ក្រុមទាំងអស់ត្រូវធ្វើការទំនាក់ទំនងទៅសមាជិក ក្នុងក្រុមរបស់ខ្លួនដើម្បីជូនដំណឹងឲ្យត្រឡប់ចូលធ្វើការវិញក្នុងរយៈពេល ២ ថ្ងៃ ។

៣- ភាគីទាំងពីរយល់ព្រមទទួលយក ការផ្តល់ប្រាក់ឈ្នួល **៥០ភាគរយ** សម្រាប់កម្មករម្នាក់ៗចំនួន៦៤៦ នាក់ ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារខាងលើនេះ ។

៤- ក្នុងករណីបងប្អូនកម្មករ មិនបានចូលធ្វើការវិញតាមការកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តតាមច្បាប់ស្តីពីការងារ និង បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ៕

ក្រោយពីបានជជែក និងពិភាក្សាគ្នារួចមក ភាគីទាំងពីរយល់ស្របទទួលយកលក្ខខណ្ឌ ខ្លឹមសារនៃកិច្ចប្រជុំនេះ និងអនុវត្តចាប់ពីពេលនេះតទៅ ។

ថ្ងៃអង្គារ ៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២

ស្នាមមេដៃតំណាងកម្មករនិយោជិត

នាយកក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន ហ្ស៊ីជាង ហេងហ្វេង ថប លេហ្សឺរ (ខេមបូឌា) ឯ.ក
ZHEJIANG HENGFENG TOP LEISURE (CAMBODIA) CO., LTD
KINGDOM OF CAMBODIA